# ព្រះរាជក្រម

# ស្តីពី

# ការបង្កើតក្រសួងធនធានទឹក និងឧតុនិយម

នស/រកម/០៦៩៩/០៨

## យើង

## ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្ម មាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ដែលប្រកាសអោយ ប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ប្រកាសអោយប្រើ

ច្បាប់ស្តីពី ការបង្កើតក្រសួងធនធានទឹក និងឧតុនិយម ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៩ នាសម័យប្រជុំរដ្ឋសភា លើកទី២ នីតិកាលទី២ និងដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាម លើទំរង់និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ១៩៩៩ នាសម័យប្រជុំពេញអង្គ លើកទី១ នីតិកាលទី១ ហើយនិងដែលក្រុមប្រឹក្សាធម្មនុញ្ញ ប្រកាសថា ស្របទាំងស្រុងនិងរដ្ឋធម្មនុញ្ញ មានសេចក្តីសំរេចទាំងស្រុងដូចតទៅ :

មាត្រា ១ :

ត្រូវបានបង្កើតក្រសួងធនធានទឹក និងឧតុនិយមចំណុះរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២ :

ក្រសួងធនធានទឹក និងឧតុនិយមមានសមត្ថកិច្ចដឹកនាំនិងគ្រប់គ្រងលើវិស័យធនធានទឹកនិងឧតុនិយមនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣ :

ក្រសួងធនធានទឹក និងឧតុនិយមត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ដែលអាចអមដោយរដ្ឋលេខាធិការ និង/ ឬអនុរដ្ឋលេខាធិការតាមការចាំបាច់ ។

មាត្រា ៤ :

ការរៀបចំរចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅនៃ ក្រសួងធនធានទឹក និងឧតុនិយមត្រូវបានកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៥ :

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ :

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានទូលបង្គំថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ : ១២៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៩

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ហត្ថលេខា និងត្រា**

**ណារី ភាន់**